ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ : ០២៨ ស ណ ន

# សេចក្តីណែនាំ

## ស្តីពី

## ដំណើរការរៀបចំកន្លែងប្រជុំជាសាធារណៈរបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

ចាប់តាំងពីកិច្ចប្រជុំចូលកាន់តំណែង កិច្ចប្រជុំលើកទី១ កិច្ចប្រជុំលើកទី២ និងកិច្ចប្រជុំលើកទី៣ របស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌមក ក្រសួងមហាផ្ទៃបានពិនិត្យឃើញថា ដំណើរការនៃកិច្ចប្រជុំនីមួយៗ ត្រូវបានរៀបចំ និងប្រព្រឹត្តទៅស្របតាមគោលការណ៍នៃ លិខិតបទដ្ឋាន ដែលបានកំណត់ និងស្ថិតក្នុងបរិយាកាសល្អប្រសើរ មានលក្ខណៈប្រជាធិបតេយ្យ តម្លាភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ។ ក្រុមប្រឹក្សាប្រភេទនីមួយៗ បានខិតខំសម្របសម្រួលដំណើរការប្រជុំ និងបានពិនិត្យ អនុម័តនូវ**ដីកា** ស្តីពីបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន បានចប់សព្វគ្រប់ និង ទទួលបានលទ្ធផលគួរជាទីមោទនៈ ។

ទន្ទឹមនឹងលទ្ធផលល្អប្រសើរខាងលើ ក្រសួងមហាផ្ទៃក៏បានពិនិត្យឃើញថា កិច្ចប្រជុំក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ នៅមានជួបបញ្ហាលំបាកមួយចំនួន ក្នុងរៀបចំចាត់ចែងកន្លែងអង្គុយប្រជុំសម្រាប់ប្រធាន ឬអធិបតីនៃអង្គប្រជុំ សមាជិកក្រុមប្រឹក្សា អភិបាល គណៈអភិបាល មន្ត្រីជំនាញពាក់ព័ន្ធ និងសាធារណជន ដែលចូលរួម ។

ដើម្បីឱ្យដំណើរការ នៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាប្រភេទនីមួយៗ ប្រព្រឹត្តទៅតាមគោលការណ៍ដូចមានចែងក្នុងមាត្រា៦៣ មាត្រា៦៤ មាត្រា៦៥ មាត្រា១៤៨ និងមាត្រា១៤៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមានលក្ខណៈឯកភាពទៅលើការរៀបចំកន្លែងប្រជុំរបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌនោះ ក្រសួងមហាផ្ទៃ សូមធ្វើការណែនាំអំពីការរៀបចំកន្លែងប្រជុំជាសាធារណៈរបស់ក្រុមប្រឹក្សាតាមប្រភេទនីមួយៗ ដូចខាងក្រោម :

## ក-ការរៀបចំទីកន្លែងប្រជុំ

### ១-កន្លែងសម្រាប់ប្រធានក្រុមប្រឹក្សា ឬអធិបតីនៃអង្គប្រជុំ និងអភិបាល អភិបាលរង

ការរៀបចំកន្លែងប្រជុំសម្រាប់ក្រុមប្រឹក្សាប្រភេទនីមួយៗ ត្រូវបានរៀបចំជា**រាងចតុកោណកែង** (ដូចមានគំរូជូនភ្ជាប់) ដោយត្រូវរៀបកន្លែងអង្គុយរបស់ប្រធានក្រុមប្រឹក្សា ឬ អធិបតីនៃអង្គប្រជុំ ទល់មុខគ្នាជាមួយតុអង្គុយប្រជុំរបស់អភិបាល។ នៅជួរតុជាមួយអភិបាល អាចរៀបចំកន្លែងអង្គុយសម្រាប់អភិបាលរង ។

### ២-កន្លែងសម្រាប់សមាជិកក្រុមប្រឹក្សា ប្រធាន ឬតំណាងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា និងសាធារណជន

សមាជិកក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវបានរៀបចំកន្លែងអង្គុយប្រជុំតាមជួរនីមួយៗ ដែលស្ថិតនៅទល់មុខគ្នា ។ ប្រធាន ឬតំណាងគណៈកម្មាធិការនានាដែលបានអញ្ជើញចូលរួមប្រជុំ ត្រូវរៀបចំកន្លែងអង្គុយនៅជួរជាមួយសមាជិកក្រុមប្រឹក្សា ( ករណីសមាជិកក្រុមប្រឹក្សាមានចំនួនតិច ) ឬនៅជួរខាងក្រោយសមាជិកក្រុមប្រឹក្សា ។ ក្នុងករណី មានសាធារណជនអញ្ជើញចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សានោះ នៅជួរខាងក្រោយសមាជិកក្រុមប្រឹក្សា អាចរៀបចំកន្លែងរបស់សាធារណជនដែលចូលរួម អាស្រ័យទៅតាមស្ថានភាពទីកន្លែង ឬសាលប្រជុំរបស់ក្រុមប្រឹក្សា ។

### ៣-សមាសភាពចូលរួម ដែលត្រូវអង្គុយក្រោយអភិបាល និងអភិបាលរង

នៅជួរបន្តបន្ទាប់ ខាងក្រោយអភិបាល និងអភិបាលរង ត្រូវរៀបចំកន្លែងអង្គុយប្រជុំសម្រាប់ប្រធានអង្គភាពនានានៃសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងប្រធានមន្ទីរ អង្គភាព ការិយាល័យជំនាញខ្សែបណ្តោយនានាទៅតាមស្ថានភាពសាលប្រជុំ ។

## ខ-ការចាត់ចែង និងការរៀបចំកិច្ចប្រជុំក្រុមប្រឹក្សា

នាយករដ្ឋបាល ( ក្នុងករណីមិនទាន់តែងតាំងនាយករដ្ឋបាល នាយខុទ្ទកាល័យសាលារាជធានី ខេត្ត និងប្រធានមន្ទីរសាលាក្រុង ស្រុក ខណ្ឌ ) ត្រូវដឹកនាំលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សា ដើម្បីធ្វើជាសេនាធិការជូនក្រុមប្រឹក្សាក្នុងការធានាដល់ការរៀបចំ និងបែងចែកលិខិតអញ្ជើញប្រជុំ ការរៀបចំទីកន្លែងប្រជុំ ការចាត់ចែង និងគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពទូទៅ ទាំងក្នុង និងក្រៅបរិវេណសាលប្រជុំ រួមទាំងការសម្របសម្រួលឱ្យសមាជិកដែលចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សា មានកន្លែងអង្គុយប្រជុំបានត្រឹមត្រូវទៅតាមទីកន្លែង ដែលបានកំណត់រៀបចំទុកជាមុន ព្រមទាំងរៀបចំកំណត់ហេតុគ្រប់កិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សា ។

នាយករដ្ឋបាល ( ក្នុងករណីមិនទាន់តែងតាំងនាយករដ្ឋបាល នាយខុទ្ទកាល័យសាលារាជធានី ខេត្ត និងប្រធានមន្ទីរសាលាក្រុង ស្រុក ខណ្ឌ ) ត្រូវសម្របសម្រួល និងផ្តល់ព័ត៌មានដល់សាធារណជន ដែលមានបំណង

ចូលរួមក្នុងកិច្ចប្រជុំជាសាធារណៈរបស់ក្រុមប្រឹក្សា ចាំបាច់ត្រូវធ្វើការចុះឈ្មោះយ៉ាងតិចមួយ (០១) ថ្ងៃ មុនថ្ងៃប្រជុំក្រុមប្រឹក្សា ដើម្បីត្រៀមរៀបចំទីកន្លែងជូន ។ ក្នុងករណីកន្លែងត្រៀមសម្រាប់សាធារណជន មានចំនួនកំណត់ ត្រូវបានផ្តល់អាទិភាព កន្លែងអង្គុយសម្រាប់អ្នកដែលបានមកចុះឈ្មោះមុន ជាបន្តបន្ទាប់ទៅតាមចំនួនកន្លែង ដែលបានត្រៀមបំរុង ។

ទទួលបានសេចក្តីណែនាំនេះ ក្រុមប្រឹក្សា គណៈអភិបាលរាជធានី ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង ក្រុមប្រឹក្សា គណៈអភិបាលស្រុក ក្រុមប្រឹក្សា គណៈអភិបាលខណ្ឌ និង អង្គភាពដែលពាក់ព័ន្ធ ត្រូវចាត់ចែងផ្សព្វផ្សាយ និងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០០៩

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**ចម្លងជូន :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នសមាជិក គ.ជ.អ.ប
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

*( ដើម្បីជូនជ្រាបជាព័ត៌មាន )*

- ឯកសារ កាលប្បវត្តិ

# លំនាំដំណើរការរៀបចំកន្លែងប្រជុំ
# របស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

